«ខ្មោច»

ពាក្យមិនសូវច្បាស់របស់កូនប្រុសវ័យទើបតែបីឆ្នាំ បានធ្វើឱ្យអ្នកស្រីស៊ីណាបែរក្រោយសម្លឹង។ នាងមានអារម្មណ៍ចម្លែកពេលក្មេងប្រុសចង្អុលទៅក្រៅបង្អួច។

ជាកាយវិការដែលកូនគាត់មិនធ្លាប់ធ្វើទេ។

«ថីហ្នឹងកូន?»

«ម៉ោច!» ក្មេងស្រែកម្ដងទៀត។

ធម្មតាជីមីនៅមត្តេយ្យខ្មែរ-អង់គ្លេស គេនិយាយភាសាខ្មែរបានតិចទេ ដោយសារតែគេរៀនពីរភាសា។ ទោះយ៉ាងណា ពាក្យដែលគេទើបនឹងបានភ្លាត់និយាយចេញមក ធ្វើឱ្យម្ដាយក្មេងម្នាក់នេះសង្ស័យ ព្រោះពិតជាមិនធ្លាប់បានឮពីមុនមកឡើយ។

អ្នកស្រីស៊ីណាក្នុងវ័យ២៨ឆ្នាំជាស្ត្រីអភិជនដ៏មានរូបឆោមលោមពណ៌។ គាត់ដើរទៅក្បែរកូនប្រុសនិងលូកកាន់ស្មាតូចរបស់គេ មិននឹកស្មានថា ត្រឹមប៉ុណ្ណឹងក្មេងក៏ភ្ញាក់ជាខ្លាំង រួចបង្ហាញអាការៈញាប់ញ័រអស់រាងកាយ។

ម្ដាយភ័យគាំងបន្តិចចំពោះកាយវិការចម្លែក។

បែរមករកម្ដាយដោយទឹកមុខស្លេក ក្មេងប្រុសមានសភាពជំរុញធ្វើឱ្យអ្នកស្រីផ្អើមភ័យ។ ណាមួយក្មេងប្រុសស្រវាឱបម្ដាយភ្លាមៗ ធ្វើឱ្យអ្នកស្រីស៊ីណាប្រញាប់អង្គុយចុះផ្ទប់កូនផ្ទាល់នឹងដើមទ្រូង។

ខ្លួនប្រាណក្មេងប្រុសត្រជាក់ស្រេង។

ការណ៍នេះធ្វើឱ្យអ្នកស្រីរឹតតែមានចិត្តចម្លែកថែមឡើង។ គាត់លើកកូនប្រុសឡើងមកឃើតៗ ដោយលួចលបសម្លឹងមួយឆ្វាច់ទៅក្រៅបង្អួច។

សួនច្បារខាងក្រៅ មានភ្លៀងធ្លាក់រពុយមកតិចៗ។ ពីនេះទៅកន្លែងដែលសន្តិសុខអង្គុយយាមមានពន្លឺភ្លើងឆ្វាំង ហេតុអីបានជាយប់នេះសួនច្បារមើលទៅនៅតែស្រអាប់?

«មិនអីទេកូន!»

ដោយក្មេងនៅតែបន្តឱនគេចមុខជាមួយនឹងទ្រូងម្ដាយ អ្នកស្រីវ័យក្មេងក៏ខ្សឹបៗបន្តថា៖

«កុំភ័យៗ»

ក្មេងប្រុសតោង-កម្ដាយជាប់ហាក់ដូចជាកំពុងភ័យខ្លាចរអាចំពោះរឿងអ្វីមួយ។

«តោះទៅបន្ទប់យើងវិញ!»

ដើរកាត់ផ្ទះបាយឃើញយាយមេផ្ទះឈ្មោះមិន កំពុងរៀបរយតុអាហារ។

«ចាំយកបបរជីមីមកលើមកមីង!»

«ចាំលោកជំទាវ!»

អ្នកស្រីស៊ីណា គឺជាភរិយារបស់ម្ចាស់ធនាគារដ៏ធំមួយនៅកណ្ដាលក្រុងភ្នំពេញ ប៉ុន្តែនៅក្នុងផ្ទះនេះ មិនមានមនុស្សច្រើនក្រៅរស់នៅឡើយ ក្រៅពីយាយមិន និងក្មួយស្រីៗគាត់ពីរនាក់ទៀត ដែលមកជួយធ្វើការក្រៅម៉ោងរៀនសូត្ររបស់ពួកគេ។ ធម្មតាពួកគេតែងវិលត្រលប់ទៅផ្ទះក្រោយបាយល្ងាចនិងរៀបចំក្នុងក្រៅរួចរាល់ ដូច្នេះរាល់ពេលយប់មានតែយាយមិន ដែលស្នាក់នៅជាន់ខាងក្រោមក្បែរផ្ទះបាយ ហើយមានអ្នកយាមពីរនាក់ ឆ្លាស់វេនគ្នាគេងក្បែរតូបយាមនៅខាងមុខរបងផ្ទះ។

ក្រាក....ស្នូរទ្វារបើកចូលមក មិនមែនយាយមិនទេ....បែរជាអ្នកផ្សេង

«ងាប់ហើយបង! ខ្ញុំភ្ញាក់ព្រើត!»

«ទាំងម៉ែទាំងកូន តោងដៃគ្នាជាប់ម្ល៉េះ?!»

«កូនយើងប្លែកណាស់បងថ្ងៃនេះ!»

«មានអីប្លែក?»

ទឹកមុខប្ដីស្រស់ស្រាយហើយចាប់ផ្ដើមលាមកទទួលយកកូនប្រុសទៅពរកាន់ ប៉ុន្តែកូនប្រុសនៅបិទភ្នែកតោងទ្រូងម្ដាយជាប់មិនព្រមលែងដៃទៅរកឪពុកទេ។

«កើតអីគេ? មកៗប្រាប់ប៉ាសិនមើល៍!»

នេះគឺលោកវិសិដ្ឋនាយកធនាគារដ៏ធំមួយកណ្ដាលក្រុងភ្នំពេញ។ គាត់និងភរិយារៀបការបាន៧ឆ្នាំហើយ។

ស៊ីណាហុចកូនទៅឱ្យស្វាមីទាំងធ្វើមុខស្ងួត។ បុរសស្ទុកស្ទម្ភឱនសម្លឹងមុខកូនហើយថើបល្ងួងសួរ៖

«ប៉ាទេតើជីមី ប៉ាទេ!»

បានឪពុកឱបថើប ក្មេងចាប់ផ្តើមយំឡើង ដូចជាទើបតែបានគាំងនៅក្នុងភាពរន្ធត់អ្វីម្យ៉ាង។

«អម្បាញ់មិញ.....មិនដឹងថា....កូនបានឃើញអ្វីដែលក្រៅបង្អួចទេបង! ប៉ុន្តែកូនខ្លាចខ្លាំង!»

ប៉ាមិនមាត់ក៏ឈោងទៅទាញបើកវាំងននហើយសម្លឹងរេវិលរល់នៅបរិស្ថានខាងក្រៅ។ គាត់ងាកមកថើបលួងកូនទៀតព្រោះកូននៅលើដៃនៅឡើយ។

«គ្មានស្អីទេ ឃើញទេ មានតែពូកឃ្លោកនិងពូង៉ា កំពុងយាម!»

យប់នោះពេលលោកប្តីនាំកូនចូលគេងស្រួលបួលហើយ ចាប់ផ្តើមជួយរៀបចំចានក្បានជាទម្លាប់របស់ស៊ីណាដែលជាស្ត្រីមិនទំយើខ្ជិលទេ។

យាយមិននៅតែឃាត់ដូចរាល់ដង៖

«លោកជំទាវទុកនៅនេះហើយ!»

«អត់អីទេ មីងលាងចានទៅ ផ្លែអស់នេះខ្ញុំរៀបចំទុករំលែកទៅអ្នកយាមហូបខ្លះ!»

«ចាំ!»

គាត់លាងចានផងងាកមកលបមើលកិរិយាកុលនារីដោយសរសើរលបលួចក្នុងចិត្ត។

«មីងអ៊ំ្ន! ល្ងាចមិញនេះ ជីមីចង្អុលទៅក្រៅហើយនិយាយថាខ្មោច!»

យាយមិនឮកាលណាក៏ហាក់ដូចជាផ្អើងវិញលែងកម្រើក។ សន្សឹមៗយាយក្រឡេកទៅសម្លឹងក្រៅបង្អួចដែរ។ នៅពេលនោះអ្នកស្រីបន្ថែមមកទៀតថា៖

«ពេលហ្នឹងខ្ញុំលូកដៃកាន់ជីមី គេភ្ញាក់ហើយភ័យរហូតដល់មិញប៉ាគេឱបលួងទើបគេងលក់បាត់ខ្លាច!»

ស្ត្រីអ្នកធ្វើការនៅតែផ្ទឹងសម្លឹងទៅក្រៅ ធ្វើឱ្យជំទាវក្មេងតឿនខ្សឹបសួរបន្ថែមឡើងទៀត៖

«ម៉េចទៅមីង?»

ដឹងថាអ្នកស្រីកំពុងនៅរង់ចាំប្រតិកម្មខ្លួន មេផ្ទះក៏ងាកមកសម្លឹងមើលអ្នកស្រីដ៏ស្រស់ស្អាតដោយទឹកមុខព្រួយបារម្ភ៖

«នៅស្រុកខ្ញុំ បើក្មេងនិយាយចឹង គេទុកថាមិនល្អទេជំទាវ!»

ដៃចិតផ្លែឈើជំទាវក៏ចាប់ផ្ដើមរង្វើល។ សាជាថ្មីយាយមិនខ្លួនគាត់ ក៏ងាកបែរក្រោយសម្លឹងទៅក្រៅបង្អួចម្ដងទៀត។

«ឥឡូវអ្នកប្រុសជីមីយ៉ាងម៉េចទៅហើយទាន?!»

«អត់អីទេគេងហើយ!»

គាត់ដើរមកក្បែរហើយនិយាយទៀតៈ

«លោកជំទាវស្ងួត្រធម៌ដាក់ក្បាលកូនផង!»

«ចាំខ្ញុំដឹងហើយមីង! ខ្ញុំបានធ្វើហើយ!»

«ចាំស្អែកព្រឹកចាំមីងសួរគេពីរឿងនេះឱ្យ យប់ហើយ.....យើងកុំនិយាយអី! ហើយ....ក៏..... កុំទុកឱ្យនៅម្នាក់ឯង! ជំទាវឆាប់ឡើងទៅគេងក្បែរផងទៅ!»

«អត់អីទេ ខ្ញុំ.....ខ្ញុំអាងថា ឪពុកគេនៅនោះ!.....អ៊ីចឹងខ្ញុំឡើងទៅហើយ!»

«ចាស៎ លោកជំទាវឆាប់ទៅសម្រាន្តទៅទាន!»

អ្នកស្រីស៊ីណាដាក់របស់របរចុះ ចាប់ផ្ដើមដើរចាកចេញពីបន្ទប់បាយ ប៉ុន្តែពេលដល់ជណ្ដើរគាត់ហាក់នឹកឆ្ងល់រឿងអ្វីមួយក៏សម្រេចចិត្តបែរក្រោយមកវិញ។ ពិតមែន ពិតជាឃើញយាយមិនម្នាក់នោះឈប់លាងចានហើយប្រញិបប្រញាប់ទាញបង្អួចបិទវិញទាំងអស់។

បានន័យថា.....គាត់ក៏មានអារម្មណ៍អត់ល្អ។

ឡើងមកដល់បន្ទប់ ប្ដីបិទភ្លើងទៅហើយ នៅតែអំពូលរាត្រី។

ភរិយាប្រះខ្លួនមកកន្លែងរបស់នាងហើយផ្ដើមខ្សឹបប្រាប់ប្ដីៈ

«បងអ្ហា តើកូនយើងឃើញអីនៅក្រៅហ្នុង?»

«អូនឯងប្រហែសឱ្យកូនឃើញរឿងខ្មោចតាមទូរទស្សន៍ច្រើនពេកទេដឹង! ប៉ុន្តែ....ឈប់គិតវែងឆ្ងាយ! យប់ហើយ! ណាមួយ បងមានរឿងល្អមួយចង់ប្រាប់!»

ប្រពន្ធទម្លាក់ទម្លាក់ចោលនូវភាពមិនសប្បាយចិត្តងាកមកសម្លឹងរបស់មួយដែលស្វាមីហុចមក។ ក្រោមភាពព្រិល របស់នេះពិតជាសក្តិសមនឹងទឹកមុខញញឹមប៉ប្រិមរបស់ប្ដី បង្ហាញថាគេសប្បាយចិត្តដែលបានធ្វើជាម្ចាស់កម្មសិទ្ធិ។

«ស្អីហ្នឹងបង? មើលមិនច្បាស់ ដូចជាភ្លុក!»

«វត្ថុបុរាណ! ដេញថ្លៃទម្រាំបាន!»

វត្ថុបុរាណជាចំណង់ចំណូលចិត្តនៃប្ដីខ្លួន នាងដឹងរឿងនេះ ហើយប្រឹងលូកដៃទទួលយកមកប្រុងពិនិត្យបែរជាត្រូវប្ដីក្ដាប់ដៃឃុំគ្រងទុកវិញ។

«បងមិនទាន់ដឹងថា ស្រីៗគេឱ្យប៉ះកាន់របស់នេះបានឬនៅទេ! ទុកដំឡើងរាសី ឡើងបុណ្យសក្តិរួចសិន សួរតាគ្រូសិន!»

«ចិញ្ចៀន?»

«ជារបស់មេកុលសម្ព័នស្ដេចត្រាញ់បុរាណ!»

«ថ្លៃកប់ពពកហើយមែនទេ! បានជាបងសប្បាយចិត្តខ្លាំង!»

«មិនមែនរាប់រយលានដុល្លារទេ! ២៤ម៉ឺន! តែទៅមុខ អាចនឹងលក់បានកប់ពពក!»

នាងស្ងាបទ្រេតខ្លួនបម្រុងចូលនិន្ទ្រាទាំងនឹកឃើញផងដែរថា ស្វាមីម្នាក់នេះតែងតែគោរពជឿតាមការបង្គាប់របស់ហោរាប្រចាំខ្លួនគេថា មានវត្ថុបុរាណមួយ ដែលត្រូវនឹងរាសីចក្ររបស់គេហើយនឹងមកដល់ក្នុងឆ្នាំនេះ។

ឥឡូវនេះជាមួយនឹងប្រាក់រាប់សិបម៉ឺនដុល្លារឬអាចលើសពីនេះ គេអាចដេញយកថ្លៃចិញ្ចៀនកុលសម្ព័ន្ធចាស់មួយ បើមិនងប់ជឿរឿងរាសីចក្រតើជាស្អីវិញ?

«គ្រាន់តែ២៤ម៉ឺនដុល្លារទេ!»

នាងនិយាយឌឺហើយសម្លឹងរបស់នោះមិនអស់ចិត្តចុចភ្លើងមើលទៀតទោះបីជាប្ដីមិនឱ្យកាន់មិនឱ្យប៉ះ។ ប្ដីងាកមកខ្សឹបឌឺវិញ៖

«ប្រាប់ហើយថា....កុំឱ្យខ្វល់ជាមួយនឹងទំហំទឹកប្រាក់បន្តិចបន្តួច! ត្រូវនិយាយថា រាប់លានបានត្រូវ!»

សម្រាប់គំនិតប្រពន្ធ គេនេះជាបុរសពូកែរកស៊ីបំផុតនៅក្នុងជីវិតរបស់នាង គេគឺជាមេគ្រួសារដែលរកលុយបានរាប់សិបលាន ដោយមិនពិបាកនាងចូលរួមអ្វី។ ដោយសារហេតុផលនេះ ស៊ីណាសូម្បីតែតវ៉ាឬស្ដាយប្រាក់បន្តិចក៏គ្មានគំនិតដែរ។

«មានឆ្លាក់អក្សរបុរាណតូចៗទៀត គេសរសេរថាម៉េចប្រាប់ប្រពន្ធផងស្ដេចវត្ថុបុរាណ?»

«គ្មាននរណាអានដាច់ទេ ជារបស់កើតមានក្រោយកកើតទឹកដី! វាចាស់ពេកណាស់!»

អួតអាងដោយសោមនស្សហើយ ប្ដីក៏ក្ដាប់ចិញ្ចៀនយកទៅដាក់បញ្ចូលលេខសម្ងាត់រក្សាដូចកំណប់នៅក្នុងទូដែក។

ក៏ជាពេលស៊ីណាបំភ្លេចអំពីចិញ្ចៀនបុរាណដោយងាកមុខមកសម្លឹងកូនប្រុសដែលកំពុងដេកលក់ស្កប់។

កណ្ដាលអាធ្រាត្រប្ដីប្រពន្ធកំពុងលង់លក់ស្លុង ស្រាប់តែត្រូវដាស់ឡើងដោយស្នូរសំឡេងមួយពីជាន់ខាងក្រោម ធ្វើឱ្យអ្នកទាំងពីរនាក់ភ្ញាក់ដូចគេកន្ត្រាក់ ស្ទុះក្រោកចោលកូនប្រុសតូចកំពុងតែនៅចំកណ្ដាល។

«ថីមីង?»

ពួកគេសួររកយាយមិនព្រោះបើមានសំឡេងខ្លាំងបែបនេះហើយមិនដែលថាគាត់មិនភ្ញាក់ឡើងនោះទេ។

«....»

គ្មានចម្លើយ។

ប្ដីប្រពន្ធសម្លឹងមុខគ្នា រួចញីភ្នែកចុះឡើងទាំងងោកងុយលាយក្ដីងឿងឆ្ងល់។ មិនយូរប៉ុន្មានក៏បបួលគ្នាចុះទៅក្រោម ឃើញអ្នកបម្រើចំណាស់ គឺយាយមិនដេកសន្លប់ផ្កាប់មុខម្នាក់ឯងនៅកណ្ដាលច្រកឡើងជណ្ដើរ។

ស៊ីណាដៃញីភ្នែកសឹងជឿថានេះត្រឹមជាសុបិន ប៉ុន្តែប្ដីរបស់នាងមានស្មារតីច្បាស់លាស់ជាងគាត់បានប្រញាប់ប្រញាល់ប្រកូកហៅអ្នកយាមនៅខាងក្រោម។

ឃ្លោកនិងង៉ា រត់ចូលមកទាំងស្រឡាំងកាំង។

អ្នកផ្ទះនេះមិនមានមធ្យោបាយអ្វីក្រៅតែពីហៅឡានពេទ្យមកបញ្ជូនយាយមេផ្ទះទៅកាន់មន្ទីរពេទ្យ។ មេផ្ទះនៅសង្គ្រោះក្នុងមន្ទីរពេទ្យ ចំណែកអ្នកស្រីក្មេងនៅចាំផ្ទះ។

ពេញមួយថ្ងៃស៊ីណាមិនបានសប្បាយចិត្តទេព្រោះកូនប្រុសនាងចាប់ផ្ដើមក្ដៅខ្លួនហើយមិនទៅសាលារៀនបាននោះឡើយ។

កូនប្រុសរបស់នាងមានអាការៈចម្លែក គេនៅតែភ័យៗ មិនញ៉ាំ មិនលេង។ កំពុងអង្គុយលើព្រំជាមួយកូនតាមដានអាការៈក្មេង ស្រាប់តែនាងមុំក្មួយរបស់យាយមិនស្ទុះឡើងមកទាំងកាន់ទូរសព្ទក្នុងដៃ។

«អ្នកស្រី ម៉ែខ្ញុំដឹងខ្លួនហើយ!»

គឺក្មួយស្រីច្បងរបស់យាយមិន និយាយទាំងភ្នែកនៅហាក់យំ ហើម។ នាងមានទម្លាប់ហៅគាត់ថាម៉ែ។

ឃើញអាការៈនេះ ក៏អ្នកស្រីស៊ីណាប្រញាប់និយាយលួងលោម៖

«អូ...មុំ! ខ្ញុំជួយអរ! កុំភ័យអីការព្យាបាលខ្ញុំរ៉ាប់រង! សំខាន់ឱ្យតែគាត់មិនអី! ហើយ....ការងារនៅផ្ទះខាងណាទុកបាន ទុកសិនទៅ ទៅជួយថែគាត់ផងទៅមុំ.....មិនដឹងថា ហេតុអីគាត់ដួលដល់ថ្នាក់នេះ?»

មុំនៅតែមិនស្បើយនាងយំអង្វរ៖

«មិនមែនទេអ្នកស្រី! គឺម៉ែខ្ញុំទទូចសុំជួបអ្នកស្រីជាបន្ទាន់!»

«ហេតុអី?»

សំណូមពរនេះធ្វើឱ្យអ្នកស្រី ស៊ីណាមានការភ័យព្រួយបារម្ភចម្លែកយ៉ាងអាថ៌កំបាំងក្នុងចិត្ត។

«ខ្ញុំ.....កូនជីមីនៅមិនទាន់ស្រួល នៅក្តៅខ្លួន!»

ក្មួយរបស់គាត់យំយែកនិយាយអង្វរបន្ថែមភ្លាម៖

«មិញខ្ញុំលើកទូរសព្ទ គាត់និយាយថា....គាត់និយាយថា.....គាត់ជិតស្លាប់ហើយ.....គាត់ចង់ជួបអ្នកស្រីដើម្បីនឹងជម្រាបរឿងដ៏សំខាន់!»

ទាំងតក់ស្លុតអ្នកស្រីស៊ីណាបានប្រញាប់ប្រញាល់បញ្ជាឃ្លោកឱ្យបើកឡានចេញទៅ ដោយទុកកូនប្រុសផ្ញើទៅនឹងមុំនៅផ្ទះ។

ទៅដល់មន្ទីរពេទ្យស្ថានភាពរបស់យាយមិនពិតជាអាក្រក់ហួសពីអ្វីដែល ស្ត្រីអភិជនកាត់ស្មាន។

គាត់រងរបួសដេកម្ទុបៗបើកភ្នែកក្រឡេតពេលឃើញម្ចាស់ខ្លួនមកដល់។

«លោកជំទាវ! លោកជំទាវឆាប់ៗ ដោះស្រាយបញ្ហាក្នុងផ្ទះចេញ!»

«មីង!....មីងមិនអីទេ! មីងកុំអស់សង្ឃឹម....កុំទម្លាក់ខ្លួនឯងឱ្យទន់ខ្សោយ!!»

គាត់ដឹងថាស្ត្រីនេះប្រឹងលួងលោមខ្លួន ឱ្យតស៊ូឡើង តែសង្វារគាត់ គាត់ដឹងច្បាស់ខ្លួនឯង តាមរយៈដង្ហើមខ្សោយទៅៗ។ យាយមិនខិតខំជំនះនិយាយកាត់ដាក់កែវភ្នែករលីងរលោងរបស់ម្ចាស់៖

«ខ្ញុំឃើញមនុស្សស្រីស្លៀកពាក់បុរាណនៅឈរកណ្តាលផ្ទះយើង! លោកជំទាវ ពិតជាមានអ្វីមួយមិនល្អនឹងកើតឡើងទៀតលើផ្ទះយើង!»

ស៊ីណាទម្លាក់ដៃទាំងពីរមករកគ្នាហើយក៏ដាក់ម្រាមចូលគ្នាដោយភ័យបារម្ភ។

ចិត្តមួយនឹកឡើងវិញ គឺនឹកឃើញដល់រឿងដែលកូនប្រុសបានចង្អុលទៅក្រៅបង្អួច។

យាយខំត្រដាបត្រដួសនិយាយ៖

«ខ្ញុំឃើញនឹងភ្នែកច្បាស់ ហើយវាបានលើកដៃចង្អុលមកខ្ញុំ! ត្រឹមកម្លាំងនៅក្នុងចុងម្រាមវា...វាអាចទាញទម្លាក់ខ្ញុំពីលើជណ្តើរមកបាន!»

នាងថប់បារម្ភណាស់ពេលស្តាប់ឮ។ ស៊ីលើកដៃស្តាំប្រាំមកក្តោបបេះដូងខ្លួនឯងកំពុងលោត។

បីថ្ងៃក្រោយមក....យាយមិនបានស្លាប់បាត់បង់ជីវិត។

សម្រាប់ស៊ីណាពិតជាពិបាកចិត្ត។

ល្ងាចនេះ នាងនៅឈរសម្លឹងទៅទូដែកដែលប្តីបានលាក់ចិញ្ចៀនត្បូងទុក។ អ្វីមួយជាចំណុចសង្ស័យធំរបស់នាង ជាការសម្រេចចិត្តចុងក្រោយនាងចាប់ផ្តើមខលទៅម្តាយ។

«ម៉ាក់ យាយមិនមេផ្ទះខ្ញុំ គាត់ផុតកាលពីព្រឹកមិញហើយ! មុនស្លាប់ ខ្ញុំធ្លាប់ជួបគាត់ម្តង គាត់.....គាត់ប្រាប់ថា ផ្ទះខ្ញុំមានមនុស្សស្រីស្លៀកបុរាណ ចង្អុលម្រាមដៃទម្លាក់គាត់ពីជណ្តើរ!»

«ព្រះ! ....»

«កូនមិនដឹងធ្វើម៉េចទេម៉ាក់! ជីមីឈឺរហូត!»

«ថ្មីៗនេះ ប្តីឯងមានទិញអ្វីចម្លែកមកផ្ទះទេ!»

អ្នកស្រីវ័យក្មេងរិះគិតងាកសម្លឹងទូដែក....

«ជា....ចិញ្ចៀនត្បូងមួយម្តាយ.....!»

«ចិញ្ចៀន.....ត្បូង?»

«បងសិដ្ឋទើបនឹងទិញមកទុក មិនទាន់បានរកគ្រូតាឱ្យមើលទេ ព្រោះគ្រូតាមិននៅខ្មែរ! គាត់ទុកក្នុងផ្ទះនៅយប់ដែលយាយមិនមានរឿង! គាត់ថាជាចិញ្ចៀនរបស់មេកុលសម្ព័ន្ធស្តេចត្រាញ់»

នាងថាដល់ត្រង់ណេះក៏នៅស្ងៀមវិញព្រោះភ័យ។ ម្តាយតឿនវិញ៖

«និយាយរឿងទាំងអស់ប្រាប់ម្តាយមក!»

**សូមរង់ចាំអានបន្តក្នុងរឿង កន្ទ្រាញឥនុចារ្យ**